2313
10/09/18

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១១៧ អនក្រ.បក


ក្រសួងពាណិជ្ជកម្ម
ចូល
លេខ 4226
ថ្ងៃទី 10 ខែ 9 ឆ្នាំ ២០18 ម៉ោង
បញ្ជូនទៅ ២៧


# អនុក្រឹត្យ
## ស្តីពី
## តួនាទី និងភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីតួនាទីនិងភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការនៃទីស្តីការគណៈរដ្ឋមន្ត្រីនិងក្រសួងនានារបស់រាជរដ្ឋាភិបាល។

**មាត្រា២ .-**

ទីស្តីការគណៈរដ្ឋមន្ត្រីមានរដ្ឋលេខាធិការប្រចាំការ១(មួយ)រូបដែលចាត់តាំងដោយសេចក្តីសម្រេចរបស់នាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រសួងនីមួយៗមានរដ្ឋលេខាធិការប្រចាំការ១(មួយ)រូបដែលចាត់តាំងដោយសេចក្តីសម្រេចរបស់នាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាមី។

**មាត្រា៣ .-**

រដ្ឋលេខាធិការប្រចាំការនៃទីស្តីការគណៈរដ្ឋមន្ត្រីនិងរដ្ឋលេខាធិការប្រចាំការនៃក្រសួងនីមួយៗមានភារកិច្ចដូចខាងក្រោម៖

- ជួយការងារទូទៅប្រចាំថ្ងៃតាមការណែនាំរបស់រដ្ឋមន្ត្រីសាមី
- ចាត់ចែង ដឹកនាំការងាររបស់ទីស្តីការគណៈរដ្ឋមន្ត្រីឬក្រសួងតាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រីសាមី
- ដឹកនាំកិច្ចប្រជុំផ្សេងៗរបស់ទីស្តីការគណៈរដ្ឋមន្ត្រីឬក្រសួងតាមការប្រគល់សិទ្ធិរបស់រដ្ឋមន្ត្រីសាមី

- ទទួលដឹកនាំការងារប្រចាំថ្ងៃក្នុងឋានៈជារដ្ឋមន្ត្រីស្ដីទី ក្នុងករណីរដ្ឋមន្ត្រីសាមីអវត្តមានឬមានភារកិច្ចមិនអាចដឹកនាំ គ្រប់គ្រងទីស្ដីការគណៈរដ្ឋមន្ត្រីឬក្រសួងបាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីសាមីប្រគល់ជូន។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ